សួស្តី នៅក្នុងរូបភាពនេះគឺយើងនឹងនិយាយអំពីការកាត់សក់ អញ្ចឹងជាធម្មតាទាំងមនុស្សស្រី និងមនុស្សប្រុស នៅពេលណាដែលសក់គាត់វែង ឬក៏នៅពេលណាដែលគាត់មិនពេញចិត្តនឹងសក់វែងរបស់គាត់ គាត់នឹងទៅរកជាងកាត់សក់ ឬក៏រកហាងកាត់សក់ ដើម្បីកាត់សក់គាត់ចេញ ទៅតាមតម្រូវការរបស់គាត់ ជាធម្មតាមនុស្សប្រុស គឺយើងមានសក់ខ្លី ភាគច្រើនគឺយើងកាត់សក់ខ្លី ចំណែកឯមនុស្សស្រី គឺមានសក់វែងជាងមនុស្សប្រុសបន្តិច ឬក៏វែងខ្លាំងតាមចំណង់ចំណូលចិត្ត អញ្ចឹងប្រសិនបើសក់គាត់វែងខ្លាំង គាត់នឹងទៅហាងកាត់សក់ ដើម្បីកាត់សក់របស់គាត់ចេញ ទៅតាមអ្វីដែលគាត់ស្រឡាញ់

ជាក់ស្តែងនៅក្នុងរូបភាពទី ១ នៅក្នុងរូបភាពទី ១ យើងឃើញមាននារីម្នាក់ អាយុគាត់ប្រហែលជា ២៥ ឆ្នាំ អញ្ចឹងនារីនោះ គាត់មានវយក្មេងគឺ ២៥ ឆ្នាំ ហើយគាត់ពាក់អាវពណ៌បៃតងដៃខ្លី គាត់មានសក់វែងពណ៌ខ្មៅ អញ្ចឹងសក់របស់គាត់ត្រឹមស្មា សក់របស់គាត់ត្រឹមស្មា ដោយយើងឃើញគាត់បានសម្លឹងឡើងលើ ភ្នែករបស់គាត់ អញ្ចឹងភ្នែករបស់គាត់សម្លឹងឡើងលើ ហើយដៃរបស់គាត់កំពុងតែចង្អុលទៅរកសក់របស់គាត់ ដែលគាត់កំពុងតែគិតថា គាត់ចង់កាត់សក់របស់គាត់ចេញ ដោយឥឡូវនេះ សក់គាត់វែងត្រឹមស្មា អញ្ចឹងគាត់ចង់បានសក់មួយទៀត ដែលយើងឃើញនៅក្នុងរូបភាពដែលគាត់កំពុងតែគិត គឺគាត់ពេញចិត្តសក់ខ្លី ដែលសក់របស់គាត់ខ្លីត្រឹមក អញ្ចឹងបានន័យថាគាត់កាត់សក់ ចង់កាត់សក់វែងគាត់ចេញ ដាក់នៅត្រឹមកវិញ ព្រោះគាត់មិនសូវចូលចិត្តសក់វែងនោះទេ អញ្ចឹងនៅក្នុងរូបភាពនេះយើងឃើញថានារីម្នាក់នោះ គាត់កំពុងតែឈរ ឬក៏គាត់កំពុងតែអង្គុយ ហើយគិតថាគាត់ចង់កាត់សក់ ដោយគាត់មិនសូវស្រឡាញ់សក់វែង ដូច្នេះហើយគាត់ចង់កាត់សក់គាត់ឲ្យខ្លីនៅត្រឹមកវិញ អញ្ចឹងគាត់បានលើកដៃមួយចំហៀង ឬក៏មួយខាង ម្ខាង ឬក៏មួយចំហៀង ឡើងលើចង្អុលទៅរកសក់របស់គាត់ ដើម្បីគិតថាតើគាត់គួរតែកាត់សក់ខ្លីដែរឬទេ។

បន្ទាប់មករូបភាពទី ២ នៅក្នុងរូបភាពទី ២ យើងឃើញថា បន្ទាប់ពីគាត់គិតរួចហើយ គាត់ក៏បានដើរមករកផ្សារ អញ្ចឹងនារីម្នាក់នោះ គាត់គិតអម្បាញ់មិញ គឺគាត់នៅផ្ទះ ហើយគាត់កំពុងតែគិតថាតើគាត់ចង់កាត់សក់ អញ្ចឹងតើគាត់គួរតែកាត់សក់របស់គាត់ដែរឬទេ បន្ទាប់មក ចូលដល់រូបភាពទី ២ នេះ គឺនារីម្នាក់នោះ គាត់បានដើរមកផ្សារ សំដៅទៅមកផ្សារ ដើម្បីរកហាងកាត់សក់ អញ្ចឹងនៅរូបភាពទី ២ យើងឃើញមានផ្សារមួយ គាត់កំពុងតែដើរចូលទៅតាមមាត់ទ្វារផ្សារនោះ អញ្ចឹងមាត់ទ្វារផ្សារ យើងហៅថា ច្រកចូលផ្សារ យើងអាចហៅបានពីរ មាត់ទ្វារ ឬក៏ច្រកចូល

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងគាត់កំពុងតែដើរសំដៅទៅរកច្រកចូលនៃផ្សារនោះ ដែលយើងឃើញនៅខាងក្រៅ យើងឃើញមានរូបតាំងលក់នៅខោអាវផ្សេងៗ អញ្ចឹងមានតាំងលក់សម្លៀកបំពាក់នៅលើតុក្កតាជ័រ អញ្ចឹងជាទូទៅផ្សារដែលលក់សម្លៀកបំពាក់ ឬក៏លក់ខោអាវ យើងតែងតែឃើញគេតាំងខោអាវរបស់គេនូវជាមួយនឹងតុក្កតាជ័រ ដើម្បីបង្ហាញដល់អតិថិជន អញ្ចឹងនៅក្នុងរូបភាពនេះ គឺគាត់កំពុងតែដើរសំដៅទៅរកផ្សារ ដោយគាត់ចូលទៅតាមច្រកចូល ដើម្បីទៅរកហាងកាត់សក់។

រូបភាពទី ៣ នៅក្នុងរូបភាពទី ៣ យើងឃើញថា បន្ទាប់ពីគាត់ចូលទៅដល់ក្នុងផ្សារហើយ គាត់ក៏បានដើរសំដៅទៅរកហាងកាត់សក់ ដែលគាត់ធ្លាប់កាត់រាល់ដង អញ្ចឹងគាត់តែងតែមកកាត់សក់នៅក្នុងផ្សារនេះ ដោយសារតែជាងកាត់សក់នៅក្នុងផ្សារនេះ គឺគាត់កាត់ឲ្យស្អាត ឬក៏គាត់កាត់ឲ្យពេញត្រូវចិត្តទៅនឹងនារីម្នាក់នោះ ដូច្នេះហើយនៅពេលណាដែលគាត់ចង់កាត់សក់ គាត់តែងតែមករកហាងនេះជានិច្ច អញ្ចឹងថ្ងៃនេះគាត់ចង់កាត់សក់គាត់ឲ្យខ្លីម្តងទៀត ដូច្នេះហើយគាត់ក៏បានដើរចូលផ្សារ ដើម្បីរកសំដៅរកហាងកាត់សក់មួយនេះ ដែលនៅក្នុងផ្សារ ដែលយើងឃើញនៅក្នុងហាងកាត់សក់នេះ យើងឃើញមាននៅខាងក្នុង នៅខាងក្នុងយើងឃើញមានកៅអីសម្រាប់អង្គុយចំនួនពីរ ហើយមានមនុស្សម្នាក់ កំពុងតែអង្គុយលើកៅអី ដែលមានជាងកាត់សក់មួយ កំពុងតែឈរកាត់សក់នៅខាងក្រោយ អញ្ចឹងជាងកាត់សក់គឺគាត់ពាក់អាវពណ៌សដៃវែង ស្លៀកខោពណ៌ស ស្បែកជើងគាត់ពណ៌ខ្មៅ ជាងកាត់សក់នោះគឺជាមនុស្សប្រុស អញ្ចឹងជាងកាត់សក់គឺជាមនុស្សប្រុស ហើយយើងឃើញសក់គាត់គឺខ្លី ដៃរបស់គាត់ម្ខាងកំពុងតែកាន់កន្ត្រៃកាត់សក់ ដៃម្ខាងទៀតកំពុងតែកាន់ឧបករណ៍សម្រាប់ឈូសជើងសក់ អញ្ចឹងដៃគាត់សងខាងគឺមានពីរ មួយឧបករណ៍សម្រាប់ឈូសជើងសក់ មួយទៀតកាន់កន្ត្រៃសម្រាប់កាត់សក់ ដែលយើងឃើញមានមនុស្សម្នាក់កំពុងតែអង្គុយលើកៅអី ដើម្បីឲ្យជាងកាត់សក់នោះកាត់សក់ឲ្យ អញ្ចឹងបុរស ឬក៏នារីម្នាក់នោះ ដែលជាអតិថិជនរបស់ជាងកាត់សក់ កំពុងតែអង្គុយលើកៅអី ដោយខ្លួនរបស់គាត់គ្របនឹងក្រណាត់មួយ អញ្ចឹងជាធម្មតា នៅពេលដែលគេកាត់សក់ គេតែងតែគ្របខ្លួនអតិថិជនជាមួយនឹងក្រណាត់ ដើម្បីចៀសវាងសក់ជ្រុះទៅលើសម្លៀកបំពាក់របស់អតិថិជនរបស់គេ។ អញ្ចឹងនៅក្នុងរូបភាពទី ៣ នេះ គឺនារីម្នាក់នោះ គាត់បានដើរមកដល់ហាងកាត់សក់ដែលគាត់ចង់កាត់ ដើម្បីឲ្យសក់គាត់ខ្លី។

មកដល់រូបភាពទី ៤ នៅក្នុងរូបភាពទី ៤ យើងឃើញថា បន្ទាប់ពីនារីម្នាក់នោះ គាត់បានដើរមកដល់ហាងកាត់សក់ហើយ អញ្ចឹងនារីម្នាក់នោះ

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

គាត់ក៏បានចូលទៅក្នុងហាងកាត់សក់នោះ ដើម្បីឲ្យជាងកាត់សក់ឲ្យ
អញ្ចឹងនៅពេលដែលគាត់ចូលទៅដល់ហាងកាត់សក់
ជាងកាត់សក់ក៏បានទទួលនារីម្នាក់នោះយ៉ាងរាក់ទាក់ ដោយសារតែជាទូទៅនៅកន្លែងកាត់សក់
ក៏ដូចជានៅកន្លែងលក់អីវ៉ាន់នានា ឬក៏កន្លែងលក់ទំនិញនានា
ម្ចាស់ហាងតែងតែយកចិត្តទុកដាក់ជាមួយនឹងភ្ញៀវ ដូច្នេះនៅពេលដែលឃើញភ្ញៀវចូល
គេតែងតែរួសរាយរាក់ទាក់ដាក់ភ្ញៀវជានិច្ច អញ្ចឹងភ្ញៀវឬអតិថិជន
គឺតែងតែត្រូវបានទទួលរាក់ទាក់ដោយម្ចាស់ហាង។ ជាក់ស្តែងនៅក្នុងរូបភាពនេះ គឺម្ចាស់ហាង
គាត់បានទទួលរាក់ទាក់នារីនោះ ហើយឲ្យនារីនោះ គាត់ផ្តេកខ្លួន ឬក៏ដេក
ដោយដាក់ក្បាលរបស់គាត់ទៅលើឡាបូសម្រាប់កក់សក់ អញ្ចឹងមុននឹងគាត់កាត់សក់
គាត់ចង់ឲ្យជាងកក់សក់គាត់សិន ព្រោះថាសក់គាត់វែង ដូច្នេះគាត់ពិបាកនឹងកក់សក់ខ្លួនឯងណាស់
អញ្ចឹងហើយទើបគាត់មករកហាងកាត់សក់ដើម្បីកក់សក់ជាមុនសិន ប្រសិនបើមនុស្សប្រុស
យើងកម្រទៅហាងកាត់សក់ ដើម្បីឲ្យគេកក់សក់ណាស់ ដោយសារតែសក់មនុស្សប្រុសគឺខ្លី
អញ្ចឹងងាយស្រួលកក់ខ្លួនឯង ប៉ុន្តែសម្រាប់មនុស្សស្រីវិញ សក់គាត់វែង
ដូច្នេះហើយគាត់ពិបាកក្នុងការកាត់សក់ កក់សក់ខ្លួនឯងឲ្យស្អាត អញ្ចឹងគាត់ទៅរកជាង
ដើម្បីឲ្យគាត់កក់សក់ឲ្យ ដូចនៅក្នុងរូបភាពនេះ យើងឃើញថា នារីម្នាក់នោះ
គាត់បានអង្គុយដោយដាក់ក្បាលរបស់គាត់ផ្តេកទៅលើឡាបូសម្រាប់កក់សក់
ហើយជាងដែលកក់សក់នោះ គាត់កំពុងតែបាញ់ទឹកទៅលើក្បាលនារីម្នាក់នោះ
ដើម្បីឲ្យសក់គាត់សើម អញ្ចឹងដើម្បីឲ្យអាចកក់សក់បាន
យើងត្រូវតែធ្វើឲ្យសក់របស់យើងសើមជាមុនសិន ពីព្រោះថាប្រសិនបើសក់យើងស្ងួត
គឺយើងអត់អាចកក់សក់បានទេ ព្រោះសាប៊ូនឹងមិនមានពពុះនោះទេ ប្រសិនបើសក់យើងស្ងួត
ដូច្នេះយើងត្រូវការឲ្យសក់យើងសើមជាមុនសិន ដើម្បីអាចកក់សក់បាន
ដែលយើងឃើញនៅក្បែរឡាបូសម្រាប់កក់សក់នោះ យើងឃើញមានសាប៊ូចំនួនពីរដប
អញ្ចឹងសាប៊ូនោះគឺមានមួយ ជាសាប៊ូកក់សក់ និងមួយទៀតជាសាប៊ូបន្ទន់សក់ អាចជាសាប៊ូបន្ទន់សក់
ព្រោះថាជាទូទៅនៅពេលដែលនារីកក់សក់រួច នារីភាគច្រើនគឺគាត់តែងតែបន្ទន់សក់
ជាមួយនឹងសាប៊ូបន្ទន់សក់បន្ថែមទៀត អញ្ចឹងហើយទើបយើងឃើញនៅក្បែរឡាបូកក់សក់នោះ
គឺមានសាប៊ូចំនួនពីរដប ដែលមួយជាសាប៊ូបន្ទន់សក់ មួយទៀតជាសាប៊ូកក់សក់
សាប៊ូកក់សក់គឺជាសាប៊ូដែលធ្វើឲ្យសក់យើងស្អាត ស្បែកក្បាលយើងស្អាត អស់ក្អែល ឬក៏អស់អង្គែ
អញ្ចឹងធូលីដីដែលនៅជាប់លើក្បាលយើងហៅថាអង្គែ ហើយម្យ៉ាងវិញទៀត យើងហៅថាក្អែល
ហើយមួយទៀតគឺសាប៊ូកក់បន្ទន់សក់ អញ្ចឹងសាប៊ូបន្ទន់សក់ គឺយើងប្រើសម្រាប់បន្ទន់សក់
បន្ទាប់ពីយើងកក់សក់រួច អញ្ចឹងពេលខ្លះនៅពេលដែលយើងចង់ឲ្យសក់របស់យើងទន់
យើងត្រូវប្រើសាប៊ូបន្ទន់សក់បន្ថែមទៀត ដើម្បីឲ្យមើលទៅឃើញទន់និងរលោងល្អ។

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

បន្ទាប់មកទៀតរូបភាពទី ៥ នៅក្នុងរូបភាពទី ៥ យើងឃើញថា បន្ទាប់ពីជាងកក់សក់
គាត់បានបាញ់ទឹកទៅលើក្បាលនារីម្នាក់នោះ ឬក៏ទៅលើសក់នារីម្នាក់នោះឲ្យសើមរួចរាល់ហើយ
អញ្ចឹងគាត់ក៏បានយកសាប៊ូមកច្របាច់ដាក់លើដៃ បន្ទាប់មកគាត់ក៏បានកក់សក់ទៅលើនារីម្នាក់នោះ
អញ្ចឹងរូបភាពនេះគឺគេគាត់នៅតែផ្ដេកក្បាលទៅលើឡាបូលាងកក់សក់ដដែល
ព្រោះថានៅពេលដែលយើងកក់សក់នៅផ្ទះ យើងកក់នៅក្នុងបន្ទប់ទឹក អញ្ចឹងយើងអាចកក់សក់
ដោយមិនបាច់ផ្ដេកក្បាលទៅលើឡាបូកក់សក់ទេ ក៏ប៉ុន្តែនៅពេលដែលយើងកក់សក់នៅក្នុងហាង
យើងត្រូវផ្ដេកក្បាលទៅលើឡាបូកក់សក់ ព្រោះថាប្រសិនបើយើងមិនផ្ដេកក្បាលទេ
យើងអាចនឹងសើមខោអាវ ឬក៏ទទឹកខោអាវបាន
ម៉្យាងវិញទៀតសាប៊ូកក់សក់អាចនឹងធ្វើឲ្យប្រឡាក់សម្លៀកបំពាក់របស់យើង
ដូច្នេះបើយើងផ្ដេកក្បាលទៅលើឡាបូកក់សក់ នោះទឹកនិងសាប៊ូនឹងចូលទៅក្នុងឡាបូទាំងអស់
គឺមិនបានប្រឡាក់ដល់ខោអាវ ឬក៏សម្លៀកបំពាក់របស់យើងទេ អញ្ចឹងជាក់ស្ដែងនៅក្នុងរូបភាពនេះ
នារីម្នាក់នោះ គាត់បានផ្ដេកក្បាលរបស់គាត់ទៅក្នុងឡាបូកក់សក់
ហើយជាងបានយកសាប៊ូមកកក់សក់ឲ្យគាត់ អញ្ចឹងជាទូទៅយើងឃើញថាសាប៊ូគឺមានពពុះ
អញ្ចឹងនៅពេលដែលគាត់ចាក់សាប៊ូទៅលើក្បាលរបស់នារីម្នាក់នោះ ដែលមានសក់កំពុងតែសើមៗ
គឺសាប៊ូគឺបែកពពុះ អញ្ចឹងគាត់បានយកដៃឈ្លី ឬក៏ញីទៅលើសក់ក្បាលរបស់នារីម្នាក់នោះ
ដើម្បីឲ្យសាប៊ូពពុះ និងដើម្បីដុសក្អែលឬអង្គែចេញពីក្បាលរបស់នារីម្នាក់នោះផងដែរ
អញ្ចឹងជាងកក់សក់នឹងធ្វើបែបនេះយ៉ាងយូរ មុននឹងគេលាងជម្រះចេញ ដើម្បីឲ្យប្រាកដថា ក្អែល
ឬក៏អង្គែនៅលើក្បាលរបស់នារីម្នាក់នោះ គឺនឹងជ្រុះអស់ចេញពីសក់របស់គេ
ហើយដើម្បីឲ្យសក់របស់គេមើលទៅភ្លឺរលោងនិងស្អាត
អញ្ចឹងជាងកក់សក់គាត់ត្រូវតែញីនិងឈ្លីក្បាល នៅពេលដែលយើងកក់សក់
យើងហៅថាឈ្លីក្បាលរបស់យើង អញ្ចឹងយើងយកម្រាមដៃទៅដុសលើក្បាល អញ្ចឹងយើងហៅថាឈ្លី
អញ្ចឹងជាងកក់សក់ គាត់បានឈ្លីក្បាលរបស់នារីម្នាក់នោះ ដើម្បីដុសសម្អាតក្អែល
នៅលើក្បាលរបស់នារីម្នាក់នោះឲ្យស្អាត។

បន្ទាប់មកទៀតរូបភាពទី ៦ នៅក្នុងរូបភាពទី ៦ យើងឃើញថា បន្ទាប់ពីជាងកក់សក់
គាត់បានឈ្លីក្បាលរបស់នារីម្នាក់នោះ យ៉ាងយូររួចមក បន្ទាប់មកគេក៏បានបាញ់ទឹកលាង
លាងជម្រះសក់នោះចេញ អញ្ចឹងបន្ទាប់ពីយើងកក់សក់រួចហើយ
យើងតែងតែលាងសម្អាតនូវសក់របស់យើងឲ្យជ្រះចេញពីសាប៊ូ
ព្រោះថានៅពេលដែលយើងមិនបានលាងជម្រះសាប៊ូចេញពីសក់ក្បាលនោះទេ
អញ្ចឹងអង្គែនិងក្អែលទាំងអស់ គឺមិនបានចេញពីស្បែកក្បាលយើងនោះទេ

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ម៉្យាងវិញទៀតសាប៊ូដែលនៅកកជាប់ស្បែកក្បាលរបស់យើង នឹងអាចក្លាយទៅជាអង្គែបានផងដែរ
ដូច្នេះដើម្បីឲ្យប្រាកដថា ក្បាលរបស់យើងស្អាត លែងមានក្អែល លែងមានអង្គែ
យើងត្រូវតែលាងជម្រះក្បាលរបស់យើងជាមួយនឹងទឹកបន្ទាប់ពីយើងកក់សក់រួច
ជាក់ស្ដែងនៅក្នុងរូបភាពនេះ គឺយើងឃើញជាងកក់សក់
គាត់បានយកទុយោផ្កាឈូកមកបាញ់ជម្រះសក់របស់នារីម្នាក់នោះឲ្យជ្រះសាប៊ូ
អញ្ចឹងគាត់បានបាញ់ទៅលើក្បាលនារីម្នាក់នោះតែប៉ុណ្ណោះ ព្រោះនារីម្នាក់នោះ
គាត់មិនបានងូតទឹកនោះទេ គឺគាត់គ្រាន់តែកក់សក់ ដូច្នេះគាត់គ្រាន់តែបាញ់ទៅលើក្បាល
ដើម្បីឲ្យសើមសក់ និងដើម្បីលាងជម្រះសាប៊ូចេញពីសក់តែប៉ុណ្ណោះ អញ្ចឹងគាត់បានបាញ់
ហើយយកដៃដុសក្បាលនារីម្នាក់នោះបណ្ដើរ អញ្ចឹងគាត់ឈ្លីក្បាលបណ្ដើរ បាញ់ទឹកបណ្ដើរ
ដើម្បីឲ្យសាប៊ូជ្រះចេញពីក្បាលនារីម្នាក់នោះអស់ទាំងអស់តែម្ដង
ដូច្នេះហើយទើបយើងឃើញថាជាងកាត់សក់ គាត់បានយកដៃរបស់គាត់ទៅឈ្លីលើសក់នារីម្នាក់នោះ
ដើម្បីលាងជម្រះសាប៊ូចេញ នៅពេលដែលគាត់កំពុងតែបាញ់ទឹកស្អាត ឬក៏បាញ់ទឹកទទេ
ទៅលើសក់ក្បាលនារីម្នាក់នោះ ដើម្បីឲ្យអស់សាប៊ូ អញ្ចឹងយើងឃើញនៅលើកនារីម្នាក់នោះ
គឺមានកន្សែងមួយ គឺគាត់បង់កកន្សែង អញ្ចឹងជាទូទៅនៅពេលដែលយើងកក់សក់
នៅកន្លែងហាងកក់សក់ ជាងកក់សក់តែងតែឲ្យកន្សែងមួយមកយើង ឬក៏កន្សែងពោះគោ
ឬយើងហៅថាកន្សែងបង់ក អញ្ចឹងយើងយកកន្សែងនោះមកបង់ក
ដើម្បីចៀសវាងទឹកសើមទៅលើអាវរបស់យើង ដូច្នេះហើយយើងយកកន្សែងនោះមកទ្រាប់
ដោយយើងយកទៅបង់ក អញ្ចឹងនៅពេលដែលយើងយកកន្សែងមកពាក់នៅលើករបស់យើង
យើងហៅថាកន្សែងបង់ក។

រូបភាពទី ៧ នៅក្នុងរូបភាពទី ៧ បន្ទាប់ពីនារីម្នាក់នោះគាត់បានកក់សក់រួចរាល់ហើយ
អញ្ចឹងនៅក្នុងរូបភាពទី ៧ នេះ គឺនារីម្នាក់នោះ គាត់បានកក់សក់របស់គាត់រួចរាល់ហើយ
ដូច្នេះគាត់ក៏បានមកអង្គុយនៅលើកៅអីកាត់សក់វិញម្ដង អញ្ចឹងកៅអីកាត់សក់គឺអាចបង្វិលបាន
ជាទូទៅគឺកៅអីកាត់សក់ គឺប្លែកពីកៅអីដែលយើងអង្គុយធម្មតា
ដោយកៅអីកាត់សក់គឺយើងអាចពន្លូត ឬក៏បន្ទាបកៅអីបាន ទៅតាមកម្ពស់របស់អតិថិជន
ម៉្យាងវិញទៀតគឺយើងអាចបង្វិលបានជុំវិញទៀតផង ដោយមិនចាំបាច់បង្វិលទាំងកៅអីនោះទេ
គឺកន្លែងអង្គុយរបស់យើង យើងអាចបង្វិលបាន ព្រោះថានៅពេលដែលជាងកាត់សក់ គាត់នឹង
គាត់នឹងត្រូវការបង្វិលកៅអីរបស់យើង ដើម្បីកាត់សក់របស់យើងឲ្យបានសព្វ
អញ្ចឹងកៅអីនៅកន្លែងកាត់សក់គឺមានធ្នើរមួយសម្រាប់ដាក់ជើង
អញ្ចឹងនៅពេលដែលយើងអង្គុយលើកៅអី ជើងរបស់យើងដាក់នៅលើធ្នើរមួយ
ជាក់ស្ដែងនារីម្នាក់នេះ គាត់បានអង្គុយនៅលើកៅអីកាត់សក់ ដោយដាក់ជើងនៅលើធ្នើរ

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ចំណែកឯដៃរបស់គាត់គឺកាន់កន្សែងបង់ក ដែលគាត់បង់កសម្រាប់កក់សក់អម្បាញ់មិញ
អញ្ចឹងគាត់មានកន្សែងមួយសម្រាប់បង់ក ហើយនារីម្នាក់នោះ ក៏បានអង្គុយឆ្លុះកញ្ចក់
អញ្ចឹងនៅខាងមុខនារីម្នាក់នោះ គឺមានកញ្ចក់មួយ សម្រាប់ឆ្លុះមុខដើម្បីកាត់សក់
អញ្ចឹងនៅពេលដែលយើងកាត់សក់ ជាទូទៅតែងតែមានកញ្ចក់នៅខាងមុខ
ព្រោះថាជាងកាត់សក់ធ្វើបែបនេះ ដើម្បីឲ្យអតិថិជនអាចមើលដឹងថា
តើសក់របស់គាត់កាត់បានកម្រិតណា អញ្ចឹងប្រសិនបើគេពេញចិត្តនូវអ្វីដែលជាងកំពុងកាត់
គេអាចប្រាប់ជាងថា អាចកាត់ប្រវែងហ្នឹងបាន ហើយឈប់កាត់ទៀត អញ្ចឹងជាងហ្នឹងឈប់កាត់
ប៉ុន្តែប្រសិនបើយើងអត់មានកញ្ចក់ទេ នោះយើងមិនដឹងថា សក់របស់យើងស្អាតឬមិនស្អាតនោះទេ
អញ្ចឹងវាអាចនឹងធ្វើឲ្យយើងមិនពេញចិត្តបន្ទាប់ពីជាងកាត់រួច ដូច្នេះហើយយើងត្រូវឆ្លុះកញ្ចក់
ជាងត្រូវមានកញ្ចក់មួយ ដើម្បីឲ្យយើងឆ្លុះមើលថាតើយើងពេញចិត្តសក់យើងដែរឬទេ
នៅខាងមុខកញ្ចក់នោះ យើងឃើញថាមានធ្នើរមួយ
អញ្ចឹងមានធ្នើរមួយសម្រាប់ដាក់អីវ៉ាន់ជាងកាត់សក់ អញ្ចឹងនៅលើធ្នើរនោះ
យើងឃើញមានកន្ត្រៃកាត់សក់ មានដូចជាស្រ្តាយសម្រាប់បាញ់សក់
និងមានដូចជាជែលសម្រាប់លាបសក់ជាដើម នៅពេលដែលយើងកាត់សក់រួច
ជាងនឹងបាញ់ស្រ្តាយនៅលើសក់យើង ឬក៏លាបជែលនៅលើសក់យើងដើម្បីធ្វើម៉ូត
ឬក៏ធ្វើស្តាយផ្សេងៗឲ្យអតិថិជនទៅតាមតម្រូវការ ហើយនៅក្នុងធ្នើរនោះ
យើងឃើញមានថតចំនួនមួយ អញ្ចឹងមាន ធ្នើរនោះមានថតចំនួនមួយ ដែលថតធ្នើរនោះ
គឺសម្រាប់ដាក់កន្ត្រៃ សម្រាប់ដាក់ឡាម សម្រាប់កោរជាដើម អញ្ចឹងនៅលើធ្នើរ
និងនៅក្នុងថតធ្នើរនោះ គឺដាក់សម្ភារៈសម្រាប់កាត់សក់ទាំងអស់ ដែលនៅក្រោមធ្នើរនោះ
យើងឃើញមានធុងសំរាមចំនួនមួយ អញ្ចឹងជាទូទៅប្រសិនបើភ្ញៀវគាត់មានសំរាម
ដែលត្រូវបោះចោល គាត់បោះចូលទៅក្នុងធុង ហើយម៉្យាងវិញទៀត នៅពេលដែលយើងកាត់សក់រួច
យើងតែងតែប្រើប្រាស់ឡាមសម្រាប់កោររោមចេញ អញ្ចឹងនៅពេលដែលកោររួច
គឺជាងគាត់បានបោះសំបកឡាមចាស់ៗចូលទៅក្នុងធុង
ព្រោះថាយើងប្រើឡាមកោរសម្រាប់មនុស្សតែម្នាក់តែប៉ុណ្ណោះ សម្រាប់ឡាមមួយ
អញ្ចឹងចៀសវាងការឆ្លងមេរោគ ដូច្នេះគេប្រើឡាមតែមួយប៉ុណ្ណោះ សម្រាប់កោរ
សម្រាប់អតិថិជនម្នាក់ ដែលយើងឃើញនៅខាងក្រោយនារីម្នាក់នោះ គឺមានជាងកាត់សក់
អញ្ចឹងជាងកាត់សក់ គាត់កំពុងតែកាន់សៀវភៅមួយក្បាល ដើម្បីឲ្យនារីម្នាក់នោះ
សៀវភៅនោះគឺជាសៀវភៅម៉ូតសក់ អញ្ចឹងគាត់ហុចសៀវភៅម៉ូតសក់ទៅឲ្យអតិថិជនរបស់គាត់
ដើម្បីឲ្យអតិថិជនរបស់គាត់ជ្រើសរើសថាតើគាត់ចង់បានម៉ូតអ្វីខ្លះ អញ្ចឹងនៅក្នុងដៃជាងកាត់សក់នោះ
គាត់បានកាន់សៀវភៅម៉ូតសក់មួយក្បាល។

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

បន្ទាប់មកទៀតរូបភាពទី ៨ នៅក្នុងរូបភាពទី ៨ យើងឃើញថា
បន្ទាប់ពីគាត់បានទទួលសៀវភៅម៉ូតសក់ពីជាងកាត់សក់ហើយ នារីម្នាក់នោះ
គាត់ក៏បានបើកសៀវភៅម៉ូតសក់ ដើម្បីមើលម៉ូតសក់ដែលគាត់ពេញចិត្ត
អញ្ចឹងគាត់បានបើកម្ដងមួយទំព័រ ម្ដងមួយទំព័រ
រហូតរកឃើញទំព័រដែលមានម៉ូតសក់ដែលគាត់ពេញចិត្ត អញ្ចឹងយើងឃើញនៅក្នុងរូបភាពនេះ
គឺគាត់បានចង្អុលទៅលើម៉ូតសក់មួយដែលមានសក់ត្រឹមក អញ្ចឹងបានន័យថាសក់ខ្លី
ដែលក្រឡឹងករបស់គាត់ គឺត្រឹមត្រចៀកតែប៉ុណ្ណោះ អញ្ចឹងសក់នេះគឺសក់ខ្លីត្រឹមត្រចៀក
អញ្ចឹងអម្បាញ់មិញសក់របស់គាត់វែងត្រឹមស្មា អញ្ចឹងគាត់ចូលហាងកាត់សក់
ដើម្បីឲ្យជាងកាត់សក់ត្រឹមត្រចៀករបស់គាត់ ដូច្នេះហើយនៅពេលដែលគាត់បើកសៀវភៅម៉ូតសក់
គាត់ឃើញម៉ូតសក់មួយដែលមានសក់នៅត្រឹមត្រចៀក
អញ្ចឹងគាត់ក៏បានយកដៃចង្អុលទៅកាន់ម៉ូតសក់មួយនោះ
ដើម្បីឲ្យជាងកាត់សក់របស់គាត់ទៅតាមម៉ូតសក់ត្រឹមត្រចៀកនោះ
អញ្ចឹងគាត់ពេញចិត្តនឹងម៉ូតត្រឹមត្រចៀក ដូច្នេះហើយគាត់ក៏បានចង្អុលប្រាប់ជាងថា
គាត់ចង់កាត់ម៉ូតត្រឹមត្រចៀកនេះ។

បន្ទាប់មកទៀតរូបភាពទី ៩ នៅក្នុងរូបភាពទី ៩ យើងឃើញថា
បន្ទាប់ពីគាត់ចង្អុលម៉ូតប្រាប់ជាងកាត់សក់រួចហើយ បន្ទាប់មកជាងកាត់សក់គាត់ក៏បានយកកន្សែង
ឬក៏ផាហ៊ុម ឬក៏ក្រណាត់ធំមួយ ដើម្បីចងឬក៏គ្របពីលើនារីម្នាក់នោះ អញ្ចឹងដើម្បីកាត់សក់
យើងត្រូវប្រើប្រាស់កន្សែងមួយ ឬក៏ផាហ៊ុម យើងហៅថាផាហ៊ុម
បើភាសាសាមញ្ញយើងហៅថាកន្សែង ឬក្រណាត់គ្រប ក៏ប៉ុន្តែបើភាសាដែលយើងប្រើប្រាស់ពីមុន
ភាសាខ្មែរពីមុន យើងហៅថាផាហ៊ុម អញ្ចឹងគាត់យកកន្សែង ឬក៏ផាហ៊ុមនោះ មកគ្រប
មកលើអតិថិជនរបស់គាត់ដើម្បីកាត់សក់ ព្រោះថាប្រសិនបើគាត់មិនគ្របក្រណាត់ ឬក៏កន្សែង
ឬក៏ផាហ៊ុមនោះទេ សក់នឹងអាចធ្លាក់ទៅលើសម្លៀកបំពាក់របស់អតិថិជន
ហើយអាចជាប់នឹងសម្លៀកបំពាក់អតិថិជន ដូច្នេះវាអាចនឹងធ្វើឲ្យអតិថិជនពិបាក
អញ្ចឹងគាត់ត្រូវគ្របកន្សែង ដើម្បីឲ្យសក់ធ្លាក់លើកន្សែងរបស់គាត់ អញ្ចឹងខោអាវ
ឬក៏សម្លៀកបំពាក់របស់អតិថិជនរបស់គាត់ នឹងមិនមានជាប់សក់នោះទេ
ព្រោះថាប្រសិនបើមានសក់ជាប់ខោអាវ គឺយើងពិបាកស្លៀកពាក់ណាស់ គឺវានឹងចាក់ហើយស្មៀប
អញ្ចឹងវានឹងចាក់ៗខ្លួនយើង ដែលយើងធ្វើឲ្យយើងស្មៀប ពិបាកនៅក្នុងការស្លៀកពាក់
ដូច្នេះហើយទើបជាងកាត់សក់ គាត់យកកន្សែង ឬក៏ផាហ៊ុមមកគ្របឲ្យអតិថិជនរបស់គាត់
អញ្ចឹងនារីម្នាក់នោះ គាត់អង្គុយលើកៅអីកាត់សក់ ដោយគាត់អង្គុយនៅខាងមុខកញ្ចក់មួយ
ហើយជាងកាត់សក់យកកន្សែងមកគ្របឲ្យគាត់។

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

បន្ទាប់មកទៀតរូបភាពទី ១០ នៅក្នុងរូបភាពទី ១០ យើងឃើញថា បន្ទាប់ពីគ្របកន្សែងហើយ
ជាងកាត់សក់គាត់ក៏បានកាត់សក់របស់នារីម្នាក់នោះ ទៅតាមតម្រូវការរបស់នារីម្នាក់នោះ
ដែលបានប្រាប់គាត់ អញ្ចឹងនៅក្នុងរូបភាពនេះ យើងឃើញថា ដៃម្ខាងរបស់ជាងកំពុងតែកាន់កន្ត្រៃ
រីឯដៃម្ខាងទៀតកំពុងតែកាន់ក្រាសសិតសក់ អញ្ចឹងជាទូទៅនៅពេលដែលជាងកាត់សក់
គាត់តែងតែយកក្រាសដើម្បីសិតសក់របស់យើង ហើយដើម្បីយកទៅកាត់ អញ្ចឹងដៃរបស់ជាង
គឺម្ខាងកាន់កន្ត្រៃ និងម្ខាងទៀតកាន់ក្រាស គឺកាន់កន្ត្រៃដើម្បីកាត់ អញ្ចឹងកន្ត្រៃគឺមុត
ដូច្នេះហើយគឺយើងកាន់ដើម្បីកាត់សក់ ហើយដៃម្ខាងទៀតគឺយើងប្រើក្រាស
ក្រាសគឺមានធ្មេញវាចន្លោះៗ អញ្ចឹងក្រាសប្រៀបដូចជាបន្ទាត់មួយអញ្ចឹងដែរ ក៏ប៉ុន្តែវាអត់
អត់ត្រង់ស្អាតដូចបន្ទាត់នោះទេ ដោយក្រាសមានធ្មេញ យើងហៅថាធ្មេញ គឺមានធ្មេញចន្លោះៗពីគ្នា
ដើម្បីឲ្យយើងអាចសិតសក់បាន អញ្ចឹងគាត់សិត គាត់កាន់ក្រាសម្ខាង និងដៃម្ខាងទៀតគាត់កាន់កន្ត្រៃ
ដើម្បីកាត់សក់ឲ្យអតិថិជន ជាងកាត់សក់តែងតែធ្វើបែបនេះចំពោះគ្រប់អតិថិជនទាំងអស់
អញ្ចឹងយើងឃើញថា នៅក្នុងរូបភាពនេះ គាត់កំពុងតែកាត់សក់ឲ្យនារីម្នាក់នោះ
ទៅតាមម៉ូតដែលនារីម្នាក់នោះពេញចិត្ត ហើយសក់របស់នារីម្នាក់នោះ
មិនបានធ្លាក់មកលើសម្លៀកបំពាក់របស់នារីម្នាក់នោះទេ ដោយសក់បានធ្លាក់ទើរទៅលើផាហ៊ុម
ឬក៏កន្សែងដែលជាងកាត់សក់គ្របទៅឲ្យនារីម្នាក់នោះ ដូច្នេះនារីម្នាក់នោះ
គាត់មិនមានសក់ជាប់នៅក្នុងសម្លៀកបំពាក់របស់គាត់នោះទេ។

បន្ទាប់មកទៀតរូបភាពទី ១១ នៅក្នុងរូបភាពទី ១១ យើងឃើញថា
បន្ទាប់ពីគាត់កាត់សក់រួចរាល់ហើយ ជាងកាត់សក់គាត់បានកាត់សក់នារីម្នាក់នោះ ត្រឹមក
ឬក៏ត្រឹមត្រចៀករួចរាល់ហើយ យើងឃើញថា ជាងកាត់សក់បានយកម៉ាស៊ីនផ្លុំសក់
មកផ្លុំសក់របស់នារីម្នាក់នោះ អញ្ចឹងដោយសារតែ ជាទូទៅនៅពេលដែលយើងកាត់សក់
សក់មិនបានជ្រុះចេញពីក្បាលយើងអស់នោះទេ ដោយសក់ខ្លះគឺទើរនៅលើក្បាលរបស់យើង
សក់ខ្លះធ្លាក់ចុះ ហើយសក់ខ្លះទៀតគឺធ្លាក់ចូលទៅក្នុងក្បាលនៅក្នុងសក់ផ្សេងៗទៀត
អញ្ចឹងវាអត់ជ្រុះមកក្រោមទេ ដូច្នេះហើយ បន្ទាប់ពីកាត់សក់
ជាងកាត់សក់គាត់តែងតែយកម៉ាស៊ីនផ្លុំសក់ មកផ្លុំសក់របស់យើង
ដើម្បីផ្លុំឲ្យសក់ដែលនៅទើរលើក្បាលរបស់យើងហើរចេញទាំងអស់ អញ្ចឹងនៅក្នុងរូបភាពនេះ
យើងឃើញថា ជាងកាត់សក់គាត់បានកាន់ ដៃម្ខាងរបស់គាត់កាន់ម៉ាស៊ីនផ្លុំសក់
ដែលម៉ាស៊ីនផ្លុំសក់នោះគឺមានពណ៌ទឹកក្រូច ហើយម៉ាស៊ីនផ្លុំសក់នោះ គឺប្រើប្រាស់ភ្លើង
ដូច្នេះយើងឃើញមានខ្សែភ្លើងចំនួនមួយ ដែលដោតចេញពីជញ្ជាំង
អញ្ចឹងគាត់បានដោតខ្សែភ្លើងរបស់ម៉ាស៊ីនផ្លុំសក់នោះទៅនឹងជញ្ជាំងមួយ

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ហើយកាន់ម៉ាស៊ីនផ្លុំសក់បាញ់ខ្យល់ទៅលើក្បាលរបស់នារីម្នាក់នោះ
អញ្ចឹងម៉ាស៊ីនផ្លុំសក់គឺមានខ្យល់ខ្លាំង ដូច្នេះហើយនៅពេលដែលគាត់បាញ់ទៅលើសក់នារីម្នាក់នោះ
យើងឃើញថាសក់នារីម្នាក់នោះប៉ើង អញ្ចឹងសក់នារីម្នាក់នោះប៉ើង
ហើយកម្ទេចកម្ទីសក់ដែលគាត់បានកាត់ ក៏បានប៉ើងចេញពីក្បាលរបស់នារីម្នាក់នោះផងដែរ
អញ្ចឹងគាត់បានផ្លុំបណ្ដើរ យកដៃម្ខាងទៀតទៅជជុះ ឬក៏ទៅរលាស់សក់នារីម្នាក់នោះបណ្ដើរ
ដើម្បីឲ្យសក់ដែលនៅធ្លាក់ចូលទៅក្នុងសក់ផ្សេងៗទៀតហ្នឹង ប៉ើងចេញ
ឬក៏ខ្ចាតចេញពីសក់របស់គាត់ អញ្ចឹងគាត់បានផ្លុំសក់នារីម្នាក់នោះ
ដើម្បីឲ្យកម្ទេចកម្ទីសក់ចេញពីក្បាលរបស់គាត់ឲ្យអស់
ម្យ៉ាងវិញទៀតគឺគាត់ផ្លុំដើម្បីឲ្យសក់នារីម្នាក់នោះស្ងួត ដោយសារតែនារីម្នាក់នោះ
គាត់ទើបតែកក់សក់រួច អញ្ចឹងដើម្បីឲ្យឆាប់ស្ងួត គឺយើងប្រើប្រាស់ម៉ាស៊ីនផ្លុំសក់
ដើម្បីផ្លុំឲ្យវាឆាប់ស្ងួតដើម្បីអាចធ្វើម៉ូត ឬក៏ចាប់ស្ដាយផ្សេងៗបាន។

បន្ទាប់មករូបភាពទី ១២ នៅក្នុងរូបភាពទី ១២ បន្ទាប់ពីគាត់ផ្លុំយកកម្ទេចកម្ទីសក់
និងផ្លុំឲ្យសក់ស្ងួតរួចរាល់ហើយ ជាងកាត់សក់គាត់ក៏បានយកស្ព្រាយ
មកបាញ់លើសក់នារីម្នាក់នោះបន្ថែមទៀត
អញ្ចឹងបានន័យថាក្រោយពីគាត់កាត់សក់នារីម្នាក់នោះឲ្យខ្លីរួចរាល់ហើយ សក់នារីម្នាក់នោះ គាត់ក៏
ក៏ខ្លីជាងមុខ អញ្ចឹងខ្លីត្រឹមកទៅតាមអ្វីដែលគាត់ចង់បាន ដូច្នេះហើយជាងកាត់សក់
គាត់ក៏បានយកស្ព្រាយមកបាញ់ទៅលើសក់ក្បាលនារីម្នាក់នោះ
អញ្ចឹងជាទូទៅយើងយកស្ព្រាយមកបាញ់ ស្ព្រាយខ្លះគឺស្ព្រាយរលោង
អញ្ចឹង[...]នៅពេលដែលយើងបាញ់វាទៅលើសក់ គឺធ្វើឲ្យសក់យើងរលោង មើលទៅភ្លឺ
និងគួរឲ្យស្រឡាញ់ ហើយស្ព្រាយខ្លះទៀតគឺធ្វើឲ្យសក់យើងរឹង
អញ្ចឹងនៅពេលដែលយើងចង់លេងម៉ូតសក់ ឬក៏ចង់ធ្វើសក់ចេញជាស្ដាយ ឬក៏ម៉ូតផ្សេងៗ
សក់បះបញ្ឈរឡើងលើជាដើម យើងអាចប្រើស្ព្រាយរឹង អញ្ចឹងស្ព្រាយនោះគឺបាញ់ទៅ
បន្តិចមួយសន្ទុះគឺធ្វើឲ្យសក់យើងឡើងរឹង អញ្ចឹងយើងអាចលេងម៉ូតបាន
ប៉ុន្តែស្ព្រាយនេះគឺជាស្ព្រាយរលោង ជាទូទៅមនុស្សស្រីតែងតែប្រើស្ព្រាយរលោង
ដើម្បីឲ្យសក់របស់គាត់មើលទៅឃើញស្អាត ចំណែកឯមនុស្សប្រុស គឺយើងប្រើស្ព្រាយរឹង
ដើម្បីចាប់ម៉ូតសក់ យើងលេងម៉ូតសក់របស់យើង ដោយប្រើប្រាស់ស្ព្រាយរឹង។

បន្ទាប់មកទៀតរូបភាពទី ១៣ រូបភាពទី ១៣
បន្ទាប់ពីគាត់បាញ់ស្ព្រាយទៅលើសក់នារីម្នាក់នោះឲ្យរលោងរួចហើយ យើងឃើញថា ជាងកាត់សក់
គាត់ក៏បានយកកញ្ចក់មួយមកទៀត អញ្ចឹងនៅខាងមុខនារីម្នាក់នោះ គឺគេជាកញ្ចក់ឆ្លុះមុខមួយ

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ក៏ប៉ុន្តែកញ្ចក់នោះឆ្លុះមើលបានតែខាងមុខតែប៉ុណ្ណោះ អញ្ចឹងនារីម្នាក់នោះ
គាត់អត់អាចមើលខាងក្រោយ ឬក៏សក់ខាងក្រោយរបស់គាត់ឃើញនោះទេ
ដោយសារតែកញ្ចក់នៅខាងមុខ អញ្ចឹងហើយគាត់អាចមើលសក់ខាងមុខរបស់គាត់
ក៏ប៉ុន្តែអ្វីដែលគាត់ចង់បាន គឺគាត់ចង់បានសក់ខាងក្រោយរបស់គាត់ខ្លី
ដូច្នេះហើយគាត់ក៏បានសុំឲ្យជាងយកកញ្ចក់មួយ ដើម្បីឲ្យគាត់មើលខាងក្រោយ អញ្ចឹងរូបភាពទី
១៣ នេះ គឺជាងកាត់សក់ គាត់ក៏បានយកកញ្ចក់មួយមកឲ្យនារីម្នាក់នោះ អញ្ចឹងជាងកាត់សក់
គាត់បានឈរកាន់កញ្ចក់ពីក្រោយនារីម្នាក់នោះ អញ្ចឹងជាងកាត់សក់ គាត់ឈរក្រោយខ្នងនារីម្នាក់នោះ
ដោយកាន់កញ្ចក់ដាក់ចំក្បាលនារីម្នាក់នោះ ដាក់ក្បែរក្បាល នៅខាងក្រោយក្បាល
អញ្ចឹងធ្វើឲ្យនារីម្នាក់នោះ គាត់អាចមើលឃើញ ធ្វើឲ្យនារីម្នាក់នោះ
គាត់អាចមើលឃើញសក់របស់គាត់តាមរយៈកញ្ចក់បាន
អញ្ចឹងគាត់អាចមើលឃើញសក់ខាងក្រោយរបស់គាត់តាមរយៈកញ្ចក់
ដែលជាងគាត់ដាក់នៅខាងក្រោយនារីម្នាក់នោះ ដូច្នេះហើយគាត់អាចដឹងថា
តើគាត់ពេញចិត្តនូវសក់នោះដែរឬទេ អញ្ចឹងនារីម្នាក់នោះ គាត់ពេញចិត្តសក់ខ្លីត្រឹមក
ដូច្នេះហើយទើបជាងកាត់សក់ខ្លីត្រឹមកឲ្យនារីម្នាក់នោះ។

បន្ទាប់មកទៀតរូបភាពទី ១៤ នៅក្នុងរូបភាពទី ១៤ យើងឃើញថា បន្ទាប់ពីនារីម្នាក់នោះ
គាត់បានឃើញសក់ខាងក្រោយរបស់គាត់ហើយ
គាត់បានសម្តែងអារម្មណ៍ពេញចិត្តទៅលើសក់របស់គាត់ ដោយគាត់ស្រឡាញ់សក់ខ្លី
គាត់មិនចង់បានសក់វែងនោះទេ អម្បាញ់មិញមុននឹងគាត់កាត់ គឺគាត់មានសក់វែងត្រឹមស្មា
ក៏ប៉ុន្តែគាត់មិនបានស្រឡាញ់សក់វិញត្រឹមស្មានោះទេ គឺគាត់ស្រឡាញ់សក់ខ្លីត្រឹមត្រចៀកឬក៏ត្រឹមក
ដូច្នេះហើយគាត់ក៏បានមករកជាងកាត់សក់ ដើម្បីឲ្យកាត់ត្រឹមក
អញ្ចឹងនៅពេលដែលជាងកាត់សក់កាត់រួចរាល់ហើយ គាត់ក៏បានឆ្លុះកញ្ចក់មើលថា
តើសក់របស់គាត់គាត់ពេញចិត្តដែរឬទេ អញ្ចឹងនៅពេលដែលគាត់ឃើញសក់របស់គាត់ខ្លីត្រឹមកហើយ
នារីម្នាក់នោះ គាត់ក៏បានស្រឡាញ់សក់គាត់ និងសប្បាយរីករាយយ៉ាងខ្លាំង ព្រោះថាជាងម្នាក់នោះ
គាត់បានកាត់សក់តម្រូវចិត្តនារីម្នាក់នោះបានល្អមែនទែន អញ្ចឹងបានន័យថានារីម្នាក់នោះ
គាត់កំពុងតែពេញចិត្តនឹងម៉ូតសក់ថ្មីរបស់គាត់នេះខ្លាំងណាស់ ដោយយើងឃើញនៅក្នុងរូបភាពនេះ
គឺនារីម្នាក់នោះ គាត់បានញញឹម អញ្ចឹងគាត់ឆ្លុះកញ្ចក់ដោយទឹកមុខញញឹម
ហើយគាត់លើកដៃទាំងពីរឡើង អញ្ចឹងជាសញ្ញាប្រាប់ថា
គាត់ពេញចិត្តទៅលើម៉ូតសក់មួយនេះខ្លាំងណាស់ ដោយយើងឃើញគាត់ញញឹម
ហើយលើកដៃទាំងពីរអង្អុយឆ្លុះកញ្ចក់ អញ្ចឹងជាងកាត់សក់
នៅពេលដែលឃើញអតិថិជនរបស់គាត់សប្បាយរីករាយពេញចិត្តនឹងម៉ូតសក់នេះ

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ជាងកាត់សក់ក៏សប្បាយរីករាយដែរ យើងឃើញនៅក្នុងរូបភាពនេះ ជាងកាត់សក់គាត់ក៏ញញឹមដូចគ្នា
អញ្ចឹងយើងឃើញនៅក្នុងរូបភាពនេះ គឺជាងកាត់សក់គាត់មូរដៃអាវឡើង
ពីដំបូងគឺគាត់ពាក់អាវដៃវែង បន្ទាប់[ពី]មក [ពេល]គាត់កាត់សក់ឲ្យអតិថិជន គឺគាត់មូរដៃអាវឡើង
អញ្ចឹងដៃអាវគាត់ គាត់មូរពាក់កណ្ដាល យើងឃើញថា ដៃអាវរបស់គាត់ គឺលាត់ឡើង ឬមូរឡើង
ត្រឹមកែងដៃ ព្រោះថាប្រសិនបើយើងទុកដៃអាវវែងដើម្បីធ្វើការ គឺវាពិបាកក្នុងការធ្វើការ
ដូច្នេះហើយគាត់មូរដៃអាវឡើង ដើម្បីងាយស្រួលក្នុងការកាត់សក់ឲ្យអតិថិជន
អញ្ចឹងពួកគេទាំងពីរនាក់កំពុងតែសប្បាយរីករាយ ព្រោះថានារីម្នាក់នោះ គាត់ពេញចិត្តនឹងម៉ូតសិតថ្មី
ហើយជាងកាត់សក់ គាត់សប្បាយរីករាយ
ព្រោះថាគាត់អាចកាត់សក់តម្រូវចិត្តរបស់អតិថិជនរបស់គាត់បាន។

បន្ទាប់មកទៀតរូបភាពទី ១៥ នៅក្នុងរូបភាពទី ១៥ យើងឃើញថា បន្ទាប់ពីផ្លុះកញ្ចក់
និងពេញចិត្តសក់របស់គាត់រួចរាល់ហើយ ជាងកាត់សក់ គាត់ក៏បានយកច្រាសមកដុសទៅលើផាហ៊ុម
ឬក៏កន្សែងរបស់នារីម្នាក់នោះចេញ អញ្ចឹងគាត់យកច្រាសមកដុសសក់ដែលទើរនៅលើផាហ៊ុម
ឬក៏កន្សែងរបស់នារីម្នាក់នោះចេញ កុំឲ្យមានសក់ជាប់នឹងកន្សែងនោះទៀត
ព្រោះថាគាត់ធ្វើបែបនេះគឺដើម្បីកុំឲ្យសក់ជ្រុះទៅលើសម្លៀកបំពាក់
អញ្ចឹងជាទូទៅនៅពេលដែលយើងកាត់សក់ កម្ទេចសក់របស់យើងដែលបានកាត់
គឺតែងតែធ្លាក់ចុះក្រោម ហើយវាធ្លាក់ទៅលើកន្សែងដែលយើងបានរុំខ្លួន
អញ្ចឹងមុននឹងជាងគាត់ដកកន្សែង ឬក៏ផាហ៊ុមចេញពីខ្លួនរបស់យើង ជាងតែងតែបោសនូវកម្ទេចសក់
ដែលទើរនៅលើកន្សែងឬក៏ផាហ៊ុមនោះចេញសិន មុននឹងគាត់ដកផាហ៊ុមឬក៏កន្សែងនោះ
ចេញពីខ្លួនរបស់យើង ព្រោះថាប្រសិនបើគាត់មិនទុក ឬក៏មិនបោសកម្ទេចសក់ចេញពីកន្សែង
ឬក៏ផាហ៊ុមនោះចេញទេ សក់អាចនឹងធ្លាក់ទៅលើសម្លៀកបំពាក់របស់យើង
ដែលធ្វើឲ្យយើងពិបាកក្នុងការស្លៀកពាក់ ដែលធ្វើឲ្យយើងមានអារម្មណ៍ថាស្មៀប
អញ្ចឹងយើងមានអារម្មណ៍ថាស្មៀប ប្រសិនបើគាត់
ប្រសិនបើមានសក់នៅជាប់នឹងសម្លៀកបំពាក់របស់យើង។

បន្ទាប់មកទៀតរូបភាពទី ១៦ នៅក្នុងរូបភាពទី ១៦ យើងឃើញថា
បន្ទាប់ពីជាងគាត់បានបោសយកកម្ទេចកម្ទីសក់ចេញពីកន្សែង ឬក៏ចេញពីផាហ៊ុមរបស់
ដែលគ្របទៅលើនារីម្នាក់នោះហើយ ជាងក៏បានដកកន្សែងឬក៏ផាហ៊ុមនោះចេញពីនារីម្នាក់នោះ
អញ្ចឹងយើងឃើញថា បន្ទាប់ពីដកកន្សែងឬក៏ផាហ៊ុមចេញមក
គឺពុំមានសក់ទើរនៅលើសម្លៀកបំពាក់របស់នារីម្នាក់នោះទេ អញ្ចឹងសម្លៀកបំពាក់របស់នារីម្នាក់នោះ
គឺស្អាតដដែល ដោយមិនមានសក់ កម្ទេចសក់ ជាប់នៅលើសម្លៀកបំពាក់នោះទេ

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

បន្ទាប់មកយើងឃើញជាងកាត់សក់គឺគាត់កំពុង ដៃរបស់គាត់កំពុងតែកាន់កន្សែង
ឬក៏ផាហ៊ុមពណ៌លឿង ដែលគាត់បានដកចេញពីនារីម្នាក់នោះ ដែលជាអតិថិជនរបស់គាត់
ហើយនារីដែលជាអតិថិជន គាត់ក៏បានបង្វិលកៅអីរបស់គាត់មកក្រោយ
ដើម្បីនិយាយជាមួយនឹងជាងកាត់សក់ អញ្ចឹងអម្បាញ់មិញនារីម្នាក់នោះ
គាត់បានអង្គុយលើកៅអីកាត់សក់ ដោយខ្លួនរបស់គាត់ ដោយមុខរបស់គាត់ទល់ទៅនឹងកញ្ចក់
គឺគាត់ឆ្លុះកញ្ចក់ បន្ទាប់ពីគាត់កាត់សក់រួចរាល់ហើយ គាត់ក៏បានបង្វិលកៅអីរបស់គាត់
មករកជាងកាត់សក់វិញ ដើម្បីនិយាយទៅកាន់ជាងកាត់សក់ អញ្ចឹងពេលនេះ នារីម្នាក់នោះ
គាត់អាចនឹងនិយាយទៅកាន់ជាងកាត់សក់ថា អរគុណសម្រាប់ការកាត់សក់ម៉ូតសក់មួយនេះ
គឺខ្ញុំពិតជាពេញចិត្តនឹងម៉ូតសក់មួយនេះខ្លាំងណាស់ ហើយក៏នារីម្នាក់នោះ
អាចនឹងសួរទៅជាងកាត់សក់ថា តើអស់តម្លៃប៉ុន្មាន ឬក៏គិតថ្លៃយ៉ាងម៉េច
ហើយជាងកាត់សក់នឹងឆ្លើយទៅកាន់សំណួររបស់នារីម្នាក់នោះប្រាប់អំពីតម្លៃ
ហើយក៏និយាយអរគុណទៅកាន់នារីម្នាក់នោះ ដែលបានជ្រើសរើសហាងរបស់គេសម្រាប់កាត់សក់
អញ្ចឹងពួកគេទាំងពីរនាក់ គឺរីករាយខ្លាំងណាស់ ព្រោះថានារីម្នាក់នោះ គាត់បានពេញចិត្ត
ឬក៏គាត់បានម៉ូតសក់ ទទួលបានម៉ូតសក់ ដែលគាត់ស្រឡាញ់ ដោយគាត់ពេញចិត្ត
ចំណែកឯជាងកាត់សក់ គឺគាត់សប្បាយរីករាយ
ដោយសារតែគាត់បានកាត់សក់ឲ្យអតិថិជនរបស់គាត់ពេញចិត្ត ឬក៏ត្រូវចិត្តអតិថិជនរបស់គាត់
អញ្ចឹងពួកគេទាំងពីរនាក់ គឺមានភាពសប្បាយរីករាយយ៉ាងខ្លាំង
ដោយសារតែពួកគេពេញចិត្តនឹងការងាររបស់ពួកគេរៀងៗខ្លួន។

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.